# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍**

## កំណត់ហេតុ ស្តីពីកិច្ចប្រជុំរបស់អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ឆ្នាំពីរពាន់ប្រាំ ខែ វិច្ឆិកា ថ្ងៃទី ២៤ វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំ ២០២ របស់អង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ) នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ុំ ម៉ានិត** ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (អ.ស.អ) នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក.ក.ច.ន.យ)។

សមាសភាពចូលរួម និងរបៀបវារៈមានដូចក្នុងបញ្ជីភ្ជាប់មកជាមួយ។

ក្រោយពីបានថ្លែងអំណរគុណដល់សមាជិកអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងបុគ្គលិកនៃអង្គភាពគ្រប់គ្រងគម្រោងនៃកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ទាំងអស់ដែលបានចូលរួមប្រជុំក្នុងថ្ងៃនេះ ឯកឧត្តម **ស៊ុំ ម៉ានិត** បានជម្រាបជូនអំពីរបៀបវារៈនៃកិច្ចប្រជុំ។ បន្ទាប់មកឯកឧត្តមបានស្នើសុំអោយឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងនៃ ក.ក.ច.ន.យ រាយការណ៍អំពីការងារមួយចំនួនដែល អ.ស.អ បានធ្វើកន្លងមក

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានរំលឹកអំពីការអនុម័តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ កន្លងទៅនេះ។ ហើយឯកឧត្តមបានបង្ហាញអំពីសិក្ខាសាលាចំនួនបីលើកដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌បានធ្វើកន្លងមក នៅថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០៥ ជាមួយនឹងក្រសួង ស្ថាបន័ពាក់ពន្ឋ័ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៥ ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និង នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៥ ជាមួយសហគមន៍អ្នកផ្តល់ជំនួយ ។ កន្លងមកនេះដែរ គណប្រតិភូរបស់ក្រុមប្រឹក្សាដឹកនាំដោយឯកឧត្តម **ស៊ុំ ម៉ានិត** បានចុះទៅធ្វើការទំនាក់ទំនងផ្ទាល់ជាមួយក្រសួងដែលជាភ្នាក់ងារអនុវត្តគម្រោងកំណែទម្រង់ច្បាប់ និងតុលាការ ដែលមានជាអាទិ៍ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រសួងពាណិជ្ជកម្ម។ ជាជំហ៊ានបន្ទាប់គណប្រតិភូនេះ នឹងទៅពិភាក្សាជាមួយក្រសួងយុត្តិធម៌។ បន្ថែមទៅលើនោះ អ.គ.គ បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយអំពីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ តាមបណ្តាខេត្ត-ក្រុងមួយចំនួន ដូចជា ខេត្តតាកែវ កាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០៥ ខេត្តកំពត

និងក្រុងកែប កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៥ និងក្រុងព្រះសីហនុ នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៥។ ចំពោះសេចក្តីព្រាងបញ្ជីគម្រោង (Project Catalogue) ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានដាក់ជូនសហគមន៍ប្រទេសផ្តល់ជំនួយ ចូលរួមផ្តល់យោបល់រួចហើយ ប៉ុន្តែមិនមានការឆ្លើយតបនៅឡើយទេ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានថ្លែងអំណរគុណចំពោះឯកឧត្ត **ស៊ុយ ម៉ុងលាង** ដែលបានធ្វើរបាយការណ៍ជូនអង្គប្រជុំយ៉ាងក្បោះក្បាយពីសកម្មភាពអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការកន្លងមក ហើយឯកឧត្តមប្រធានមានប្រសាសន៍ថា នៅក្នុងមហាសន្និបាតនៃគណបក្សប្រជាជនក៏មានលើកអំពីការកែទម្រង់ច្បាប់ និងតុលាការដែលកំពុងមានការជឿនលឿនទៅមុខផងដែរ ។ បន្ទាប់មកឯកឧត្តមប្រធានបានសុំអោយ ឯកឧត្តម **សួង លាងហៃ** ធ្វើឧទ្ទេសនាមអំពីបញ្ជីគម្រោង ។

ឯកឧត្តម **សួង លាងហៃ** នាយករងអង្គភាពគ្រប់គ្រងគម្រោងបានធ្វើអត្ថាធិប្បាយអំពីដំណើរការ នៃការរៀបចំបញ្ជីគម្រោងអំពីខ្លឹមសារនៃបញ្ជីគម្រោងនោះ និងការងារដែលបានត្រៀមជាមួយគ្នានេះដែរ គឺការតាមដាន ការងារ ការរៀបចំគម្រោងលំអិត (Project Profile) ការរៀបចំផែនការការងារ (Business Plan) និងការរៀបចំសៀវភៅណែនាំ (Sector Manual) សម្រាប់វិស័យកំណែទម្រង់ច្បាប់ និងតុលាការ។

ទាក់ទងនឹងរឿងបញ្ជីគម្រោងនេះ ឯកឧត្តម **ស៊ុំ ម៉ានិត** បានចោទជាសំណួរថាតើយើងគួរធ្វើអោយបានលំអិតជាងនេះទៅទៀតឬយ៉ាងណា ដើម្បីអោយម្ចាស់ជំនួយគេជួយយើង។

ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាសមាជិកអ.ស.អ មានប្រសាសន៍ថា ទី១-គួរតែកុំលំអិតពេកនាំអោយខាតពេលវេលា ត្រូវធ្វើយ៉ាងណាដាក់គម្រោងជូនម្ចាស់ជំនួយអោយបានឆាប់រឹតតែល្អពេលដែលគេទទួលយល់ព្រមហើយ គេនឹងលំអិតជាមួយយើងជាក្រោយ ទី២-តម្រូវការចាំបាច់គឺ ធ្វើកិច្ចការងារក្នុងគោលបំណងរួមហើយបើជួបជាមួយអ្នកផ្តល់ជំនួយគួរតែទាញគេអោយងាកមករកក្នុងរឿងគម្រោងរបស់យើងវិញ។

បន្ទាប់មកឯកឧត្តម **ស៊ុំ ម៉ានិត** បានចោទជាសំណួរថា តើគួរលុបចោលអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ឬទេ ? ហើយបើទុកគួរពង្រឹងបន្ថែម ឬយ៉ាងណា ?

ឯកឧត្តម **សុខ ចិន្តា** មានប្រសាសន៍ថា ត្រូវរៀបចំយ៉ាងណាអោយធានាបាននូវប្រសិទ្ធិភាព ដើម្បីអោយប្រទេសអ្នកផ្តល់ជំនួយឃើញនូវការខំប្រឹងប្រែងរបស់យើង ចំណែកឯក្រុមការងារបច្ចេកទេសចម្រុះ (TWG) ត្រូវពង្រឹងនិងកុំអោយជាន់ភារកិច្ចជាមួយនឹង អ.ស.អ។

ឯកឧត្តម **វឿល មួន** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាសមាជិកអ.ស.អ បានឯកភាពចំពោះការរៀបចំបញ្ញើគម្រោង ដោយកុំទាន់លំអិតពេក ហើយចំពោះ អ.ស.អ មិនអាចលុបចោលបានទេ ពីព្រោះជាភ្នែកច្រមុះរបស់ ក.ក.ច.ន.យ។ ដូច្នេះសុំពង្រឹង និងបង្កើនសមាជិកសកម្ម ដោយបន្ថែមចៅក្រមចាស់ៗអោយចំជំនាញពីក្រសួងយុត្តិធម៌។

ឯកឧត្តម **ម៉ៅ ឆូរ៉ា** អនុរដ្ឋលេខាធិការ និងជាសមាជិកអ.ស.អ បានស្នើសុំអោយមានការបញ្ជាក់បំភ្លឺពីភារកិច្ចរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ។

ឯកឧត្តម **សួខ លាងហៃ** បានពន្យល់បង្ហាញពីរចនាសម្ព័ន្ធរបស់ ក.ក.ច.ន.យ អ.ស.អ និង អ.គ.គ ទៅតាមលំដាប់លំដោយជូនអង្គប្រជុំ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានមានប្រសាសន៍រំលឹកថា ក.ក.ច.ន.យ មួយឆ្នាំប្រជុំពីរដង អ.ស.អ ពីរខែប្រជុំម្តង ចំណែក អ.គ.គ  វិញ ឯកឧត្តមចង់អោយក្លាយទៅជាអគ្គលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌តែម្តង។ ចំណែកឯក្រុមការងារបច្ចេកទេសចម្រុះ គួរតែពង្រឹងអោយដើរតួនាទីជំនួស អ.ស.អ។

ឯកឧត្តម **អ៊ី ឆន** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ តំណាងឯកឧត្តម **អង្គ វង្ស វឌ្ឍានា** អនុប្រធាន អ.ស.អ បានមានប្រសាសន៍ថា អ.ស.អ មានដំណើរការស្រួលបួលហើយ។ កាលណាយើងលុប  អ.ស.អ ចោលនោះ នាំអោយមានការភាន់ច្រឡំថា អ.ស.អ ធ្វើការមិនកើត។

ឯកឧត្តម **ផាល់ ច័ន្ទតារា** មេធាវីរាជរដ្ឋាភិបាល និងជាសមាជិក អ.ស.អ បានមានប្រសាសន៍ថា មិនគួរលុប អ.ស.អចោលទេ ពីព្រោះស្នាយស្នាដៃដែលខំធ្វើកន្លងមក ដូច្នេះគួរតែពង្រឹង ឬក៏បន្ថែមសមាសភាពទៅតាមការចាំបាច់។

ឯកឧត្តម **ក្រាញ់ តូនី** អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកអ.ស.អ បានមានប្រសាសន៍សួរថា ការលុបចោល អ.ស.អ នេះ តើចំណេញ ឬខាត ? ហើយតើ អ.គ.គ  អាចរ៉ាប់រងការងារបានឬទេ ?

ឯកឧត្តម **ស៊ុំ ម៉ានិត** បានមានប្រសាសន៍ថា ចំណុចខ្លាំងរបស់ អ.ស.អ នេះគឺ ប្រធាន និងសមាជិកមួយចំនួនមានគេស្គាល់ច្រើន បើអគ្គលេខាធិការដ្ឋានមិនសូវមានគេស្គាល់ទេ។

ឯកឧត្តម **អ៊ី ឆន** បានមានប្រសាសន៍ថា អ.ស.អ អាចជួយសម្រួល និងផ្តល់ព័ត៌មានបានលឿន បើលុបចោលសមាជិកសំខាន់ៗមួយចំនួនត្រូវបាត់ ហើយយើងនឹងពិបាកក្តាប់ព័ត៌មានណាស់។

ឯកឧត្តម **វឿល មួន** បានមានប្រសាសន៍ថា សូមពង្រឹង អ.ស.អ ដោយបន្ថែមនូវសមាជិកជាចៅក្រម។

លោក **ភើត រិទ្ធិ** ជំនួយការស្រាវជ្រាវនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាសមាជិកអ.ស.អបានគាំទ្រនូវមតិរបស់ឯកឧត្តម **ក្រាញ់ តូនី** និងឯកឧត្តម **អ៊ី ដន** ហើយលោកបានលើកឡើងអំពីបញ្ហាចោទពីរយ៉ាង៖ ទី១ គឺបញ្ហាទម្រង់រចនាសម្ព័ន្ធ។ ទី២ គឺ គ្រឹះអាទិភាពនៃ អ.ស.អ តែម្តង តើមានផលប្រយោជន៍ និងភាពចាំបាច់ក្នុង ក.ក.ច.ន.យ យ៉ាងណាដែរ ?

ឯកឧត្តម **ម៉ៅ ច័ន្ទរ៉ា** បានមានប្រសាសន៍ថា អ.ស.អ បានបំពេញតួនាទីអោយ ក.ក.ច.ន.យ ចំណែកឯ អ.គ.គ ជាផ្នែកមួយរបស់ អ.ស.អ ដូច្នេះបើលុបចោលវាហាក់ដូចជារំលាយ អ.គ.គ ដែរ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានមានប្រសាសន៍ថា មូលហេតុដែលចង់រំលាយ អ.ស.អ ហើយបង្កើតអគ្គលេខាធិការដ្ឋានវិញនោះ ក៏ព្រោះតែចង់អោយអគ្គលេខាធិការដ្ឋានធ្វើការផ្ទាល់ជាមួយ ក.ក.ច.ន.យ តែម្តង។

ឯកឧត្តម **ស៊ុយ ម៉េងលាង** បានមានប្រសាសន៍ថា តួនាទីសំខាន់របស់ អ.ស.អ ដែលទទួលបន្ទុកការងារយូរមកហើយ ហើយទទួលបាននូវស្នាដៃល្អ ឯកឧត្តមមិនចង់អោយមានការលុបចោលឡើយ ពីព្រោះ អ.ស.អ មានប្រយោជន៍ច្រើន។ ចំពោះ អ.គ.គ គឺជាអគ្គលេខាធិការដ្ឋាន ។ ជាចុងក្រោយ ឯកឧត្តម សុំសំណូមពរអោយពង្រឹង និងបន្ថែមសមាជិកមកពីខាងតុលាការទៀតផង។

ឯកឧត្តម **ស៊ុំ ម៉ានិត** មានសំណើសុំតែងតាំងឯកឧត្តម **អ៊ី ដន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាអនុប្រធាន អ.ស.អ ជំនួសឯកឧត្តម **អង្គ វង្ស វឌ្ឍានា** ដែលត្រូវតែងតាំងជាអនុប្រធាននៃ ក.ក.ច.ន.យ ជំនួសឯកឧត្តម **នាង ស៊ីថុង**។

ទាក់ទងនឹងបញ្ញើគម្រោង ឯកឧត្តម **ស៊ុយ ម៉េងលាង** បានមានប្រសាសន៍ថា យើងបានដាក់ជូនកិច្ចប្រជុំជាមួយប្រទេសអ្នកផ្តល់ជំនួយរួចហើយ ហើយយើងបានជម្រាបប្រទេសផ្តល់ជំនួយដែរថា ប្រសិនបើមានគម្រោងណា ដែលនៅក្រៅបញ្ញើគម្រោងយើងនោះហើយពាក់ពន្ធ័នឹងកម្មវិធីរបស់យើងដែរនោះសូមអោយគេជួយផ្តល់យោបល់មកយើងផង។

ជាសរុបអង្គប្រជុំបានឯកភាពគ្នាដូចតទៅ៖

- រក្សាអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍អោយនៅដដែល ដោយផ្លាស់ប្តូរ និងបន្ថែមសមាសភាពចាំបាច់មួយចំនួន
- រក្សាបញ្ញើគម្រោងតាមទម្រង់សង្ខេបដដែល ដោយគ្រាន់តែសម្រួលអោយបានល្អត្រឹមត្រូវឡើងវិញ។

ជាចុងក្រោយឯកឧត្តម **ស៊ុំ ម៉ានិត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួម និងការផ្លាស់ប្តូរមតិយោបល់យ៉ាងផុសផុលរបស់សមាជិកនាពេលនេះ និងសន្យាលើកសំណូមពរទាំងឡាយជូនថ្នាក់ដឹកនាំក្រុមប្រឹក្សាពិនិត្យ និងសម្រេច។

អង្គប្រជុំពិភាក្សានេះបានបញ្ចប់នៅវេលាម៉ោងប្រាំ និងសាមសិបនាទី នាថ្ងៃដដែល។

*ធ្វើនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥*

**បានឃើញ និងឯកភាព**

ប្រធានអង្គប្រជុំ

ស៊ុំ ម៉ានិត

អ្នកកត់ត្រា

ហ៊្សួង សុកុល